**BMI0083**

# សម្ភាសន៍ជាមួយឈ្មោះ នេត ឆ្លង ភេទប្រុស អាយុ៧៨ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ អ្នកតំរង់ភ្លឺស្រែ
## សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ហ៊ិន សុធានី
## ០០:៤៧:០៧
## ២១ទំព័រ

ឆ្លង ៖ កាលពីដំបូងដើមមកស្រុកភូមិនេះវារងគ្រោះសម័យពី មកពីបារាំង ចាប់ពីបារាំងមកកើតឥស្សរៈ ចូលផុតពីសម័យឥស្សរៈមក នែន!ខ្មែរសេរី ចាប់ពីខ្មែរសេរីមកបានដល់ពួកអាយួនគេហៅវាយួនវៀរធ្មេញខ្មៅ មកយូរគ្រាន់តិច ទៅបានត្រឡប់ទៅវិញបាន ពួកឥស្សរៈ កើតឥស្សរៈឡើង ៗ ពីសង្គ្រាមណា ដល់ណាភូមិណាភូមិណៃមិនសូវដែលរងគ្រោះ រងទុក្ខតែភូមិផ្គាំនេះ ប្រទេសណាក៏មកថាផ្គាំអ្នកណាថាមកថា ផ្គាំខ្មែរណាដែលកើតទុក្ខកើតភ័យអីអន្តរាយអីក៏ឆេះស្រុក ឆេះភូមិ ៗ ដល់មកសម័យឥស្សរៈទៀត ក៏ទាស់ទែងគ្នា មកសុំប្រាក់ សុំកាកមិនបានក៏ខឹងគ្នាអុចៗផ្ទះអុចអីសណ្តែកអស់រលីងគ្មានសល់ទេ ឆេះគ្មានសល់ទេ ច្រើន អស់ ៗ ដល់អស់ពីនោះទៀតមក បានចូលអស់ខ្មែរឥស្សរៈ បានចូលពួកខ្មែរក្រហមៗ ៗ បានពួកខ្មែរក្រហមមកនៅពេលនេះមករកស៊ីអីទៅបានរកស៊ី បានកើតខ្មែរក្រហមបានហើយ ៗ បានចូលយួន ពួកយួនចូលមកដល់នេះ ៗ មកដល់បានចូល ផុតពីយួននេះមកបានកើតនែក!ខាងយើងលន់ នល់ ៗ ជំនាន់នោះលន់ នល់ក្បត់ជាតិៗហ្នឹងសម្តេចឪនោះ ថា៧៥ក្បត់គ្នាគេរត់ទៅគេចោលមក រុករានរកគ្នារត់គ្នារប៉ាត់រប៉ាយអស់ឆេះស្រុកឆេះអីទៀតហើយ ៗ ២ដងចូល២ដងចូល៣ដងៗក្នុងស្រុកផ្គាំនេះ កើតទុក្ខលំបាក ៗ នែកដែលមកបានដល់មកនែក! ដល់ពួកលន់នល់ចូលមកនេះក្បត់ទៅនឹងសម្តេចឪទៅបានរត់អស់ពេលនោះ បានចូលពួកនែក! ៗ

ធានី ៖ ខ្មែរក្រហម?

ឆ្លង ៖ ខ្មែរៗក្រហមយើង បានរត់២-៣ បានបែកបាក់គ្នារត់ បានរត់អាខ្មែរក្រហមដេញ ខ្មែរក្រហមចូលគេដេញរត់ពីខាងនោះមកចូលមកនេះពួកខ្មែរក្រហមបរទេះបរអី ដឹកនេះបានដេញគ្នារត់ឡើងទៅថៃនេះ ៗ បានពួកអាប្រជាជននៅភូមិនេះក៏នាំគ្នារត់ដែរ រត់ត្រេត្រាក់បែកខ្លះៗរត់បែកចូលទៅខាងយើងខាងរដ្ឋបាលយើងណា៎ដែលគេចូលមកពីយួនចូលមក ៗ ចូលទៅរត់

ទៅខាងនោះទៅ

បានអាពួកនោះយួនពីខាងនោះចូលមកបានរំដោះៗបានមកចូលដល់មកយើង នែក!ថ្មពួកចូលទៅបានក៏ដេញ បានដេញពួកខ្មែរក្រហមអីរត់រប៉ាត់រប៉ាយដាក់មករទេះរាប់រយ រទេះចូលមកនេះ ទៅដេញពីនេះរត់ទៅទល់គ្នាហ្នឹងថ្មពួក បែករប៉ាត់រប៉ាយនោះហើយ ។ ពួកខ្ញុំខាងថ្កាំនោះមកវិញ ទៅខាងរដ្ឋបាលយើងខាងយួនខ្មែរយើងដែលគេចូលមក គ្នាគេចូលមក រំដោះដេញពួកខ្មែរក្រហម ។ រួចដេញទៅអានេះៗបែកជា២ គេទៅខាងនេះម៉ាវគ្គទៅឯនេះ ម៉ាវគ្គរត់ទៅនៅខាងនេះ រត់ទៅនៅតាមខាងខ្មែរក្រហម នៅថ្នល់ដាច់ ។ ដល់ចូលទៅដល់ថ្នល់ ដាច់ទៅបាន កាលនោះគេនាំចូលទៅរត់ទៅនៅវៃចោលទាំងអស់ រួចបានគេហៅៗពួកខ្ញុំហើយទាំងអស់ មកក៏ចូលទៅបានគេឲ្យមកប្រជុំគ្នា ដែលពួកវៀតណាមចូលមកដល់ថ្មពួក ដុតជង្រុកដុតស្រូវ ដុះស្អីៗទាំងអស់ គេនាំទៅមើលនោះ ។ ទៅក៏ដើរតិចទៅ ពួកយួនចូលមកដល់នេះអានេះផ្អើលរត់ទៅនេះទៀត អាមុននោះ គេគម្រោងនឹងវៃចោលទាំងអស់ ដឹកអន្ទង់ដឹកអីស្រេចនៅហ្នឹងថ្នល់ដាច់នោះដំបងនោះ គេហៅនាំគ្នាមកទាំងម្ចាស់គេឲ្យមកប្រជុំតាំងពីអាយុ១៨ឆ្នាំ ចូលមកហៅមក ។ ប៉ុនដល់ហៅមកប្រជុំនៅនេះ ក៏វាមិនបានមកអស់ ដល់បែកការណ៍ៗនេះចូលដល់ត្រង់នេះ គេយកទៅវៃមិនទាន់ ។ កាន់ដំបងកាន់អី ដឹកអន្ទង់ខាងកើតថ្មពួកនេះហើយ ។ ពួកខ្ញុំអ្នកមកហើយណា មិនសូវឲ្យមកៗតាំងពីអាយុ១៨រហូតដល់៥០ ៦០ ឲ្យតែមានចាស់ ។ ប៉ុនតែមកវាមិនបាន ទៅកាលនោះក៏ពួកប៉ាវ៉ា ផ្អើលពួកប៉ាវ៉ានៅនោះ ក៏បានដាច់នេះ ចូលមកដល់វៃទៅក៏បានដុតបានរួចខ្លួននោះ មិនបានងាប់ កុំអីងាប់អស់ទៅបាត់ហើយពួកខ្ញុំវេទនា ។ ស្រុកនេះឆេះអស់ៗ រត់បែកគ្នាទៅនៅនេះខាងនេះ ទៅមកបានបែកគ្នា ដល់ទៅពួកយួនគេវៃបាន ចូលបានមកក៏គេហៅពួកខ្ញុំដែលនៅជាមួយពួកខ្មែរក្រហមនោះ ។ ខ្មែរក្រហមក៏មិនច្រើននៅនោះ នៅគ្រាន់តែ២-៣ប៉ុននោះ នៅមើលដឹកនាំប្រជាជន ទៅនៅនឹងកណ្ដាលព្រៃ ថ្នល់ដាច់ៗគេហៅថ្នល់ដាច់ ។

ធានី : នៅណាវិញ អ៊ីថ្នល់ដាច់ហ្នឹង?

ឆួង : ឆ្ងាយដែរ ។

ធានី : នៅស្រុកព្រះនេត្រព្រះ ឬក៏ស្រុកយើង?

ឆួង : ស្រុកថ្មពួក បាទ! ស្រុកថ្មពួក ពីដើមមិញគេហៅខេត្តបន្ទាយឆ្មារ គេដាក់ខេត្តបន្ទាយឆ្មារកាលនៅនោះ ។ ថ្នល់ដាច់នៅចូលមុខខាងត្បូងបន្ទាយឆ្មារ ក៏បានរកនៅបានរួច ទៅក៏គេរំដោះបានមក ។ ដល់យួនឡើងចូលមកដល់នេះទៅក៏បានៗខ្មែរក្រហមវារប៉ាត់រប៉ាយអស់គ្មានទៅ

នោះ រត់អស់ទៅបានគេហៅមក នេះឲ្យតានេះ គេឲ្យហៅមកប្រជុំ មកដោះស្រាយគ្នាដើម្បី នឹងចូល ។ ដោះស្រាយគ្នាចូលបានមកក៏គេហៅទៅ ហ៎!ត្រូវឲ្យភូមិណាក៏ទៅនៅតាមភូមិណា ក៏ទៅនៅតាមភូមិណាទៅ អ្នកទៅនោះ នៅត្រឹមព្រះនេត្រព្រះខាងត្នោលរពាក់យើងនេះ ។ បាទ!ទៅនៅនោះឯង នៅម៉ាកងពាក់កណ្ដាល ៗនៅខាងនេះខាងខ្មែរក្រហម នៅបានដល់នេះ គេហៅមកក៏ឲ្យមកប្រជុំបានគេប្រាប់ថា បងប្អូនរត់តាមខ្មែរក្រហម ទៅតាមខាងណាក៏ដោយ គេឲ្យចូលមករួបរួមនៅស្រុកនៅភូមិក៏នាំគ្នាមក....ទុកអាស្រូវអង្ករ ស្រូវស្អី ឲ្យធ្វើជង្រុក នៅតាម... បានមកវេទនា បានខាងនេះក៏ចាត់តាំងពីនោះមកក៏បាននៅសុខសាន្ត ទៅក៏ចាប់ពីដល់មកបានសុខសេចក្ដីសេចក្ដីចំរើន អង្គការរដ្ឋយើងក៏បានជួយទំនុបបំរុងឲ្យកូនចៅបានសុខបានសាន្តរហូត មានសម្ដេចហ៊ុន សែន ហើយនឹងលោក សម្ដេចនែក!ហេង សំរិន សម្ដេច ជា ស៊ីមបានហៅឲ្យមកនៅក៏រៀបចំទៅ ក៏បានសុខសាន្តរហូតដល់មកសព្វថ្ងៃក៏មានប្រដាប់ រកស៊ីដោះដារ មានឃុំ មានទ្រព្យសម្បត្តិគ្រប់ ។ ពីដើមមិញវាមានស្អី គ្មានអីទេ សុទ្ធតែគ្រឿង វាឆេះអស់រលីង វាឆេះអស់២-៣ដង ៗគ្រាន់តែទម្លាក់បាញ់អាកាំភ្លើងធំមក ៤០កាណុងមក កាលដែលនៅបានសុខសាន្តបាន ទម្រាំបានសុខសាន្តមក រងទុក្ខវេទនាខ្លាំងណាស់ភូមិនេះ ភូមិណាគេមិនសូវដែលរងវេទនាដូចភូមិនេះទេ ។ ភូមិនេះក៏ពួកឥស្សរៈបាញ់ឆេះខ្ទេចខ្ទីអស់ អាឲ្យបាយវាស៊ីមិនបានក៏រឹងខ្លាំងសម្លរៃអី គេធ្វើបាបណាស់ភូមិនេះរងទុក្ខរងវេទនាខ្លាំងណាស់ ប៉ុនសម័យ ។ បានច្រើនណាស់អ្នករងទុក្ខ ផុតពីភូមិក្រៅ ៗនៅនោះគេមិនសូវវេទនាប៉ុនភូមិនេះ ។

ធានី : ម៉េចបឹងអំនោះ?

ឆ្លង : បាទ!

ធានី : ហេតុអីបានភូមិហ្នឹងសម័យណាក៏មានសង្គ្រាម?

ឆ្លង : សម័យណាក៏សង្គ្រាម ៗវាមិនដឹងជាយ៉ាងម៉េចហ្នឹងចៅ ឲ្យតែឮថាអឺ!ផ្ដើមសង្គ្រាមហើយដល់ហើយភូមិនេះ ដល់មុនគេហើយ ។ ដឹងថាភូមិវាត្រូវយ៉ាងណា បានវាត្រូវតែគឺម៉ាសង្គ្រាមនេះ ប៉ុន្មាននេះរហូតបានដល់សព្វថ្ងៃ បានសុខសាន្ត ។ មើលតានេះ តែងតែភ័យថាយួនចូលមក នៅផ្ទះវិហារនោះ នឹកថាភ័យថាកើតអានោះហើយមិនដែលផុតផ្កាំនេះទេ ។

ធានី : គាត់ចាំសង្កេតឃើញ?

ឆ្លង : បាទ! ប៉ុនដល់អង្គការបានឮថា សម្ដេចហ៊ុនសែនលោកប្រកាសថាបានសុខសាន្តវិញហើយ ខំអរឡើង ។

ធានី ៖ ចឹងអ៊ំសម័យឥស្សរៈហ្នឹង អ៊ំដឹងចាំឆ្នាំប៉ុន្មានទេ?

ឆ្លង ៖ ឆ្នាំ នែក! ឥស្សរៈតាំងពី៥០ ៥៣សម្តេចសីហនុឡើងគង់បាននែក!ព្រះវិហារ ។

ធានី ៖ ៦៣?

ឆ្លង ៖ បាទ!

ធានី ៖ ៦៣ បានព្រះវិហារ ចឹងសម័យឥស្សរៈមានតាំងពីពេលហ្នឹង?

ឆ្លង ៖ បាទ! វាមានពេលហ្នឹង តាំងពីពេលនោះមក អាពេលចាប់មក៥៣ ។

ធានី ៖ ៥៣ ឬ៥៣?

ឆ្លង ៖ ៥៣ ។

ធានី ៖ ៥៣បានឯករាជ្យ?

ឆ្លង ៖ ៥៣សម្តេចទារហើយ បានឯករាជ្យមកចូលមក ។ ឥស្សរៈ...មុនទៀតនោះ មុន៥៣ ។

ធានី ៖ ៥៣បានឯករាជ្យ?

ឆ្លង ៖ បាទ! ដល់៥៣បានទទួលឯករាជ្យ ។

ធានី ៖ ឥស្សរៈកើតមុនហ្នឹងទៀត?

ឆ្លង ៖ បាទ! នោះខ្មែរឥស្សរៈ គេហៅអ៊ី ។

ធានី ៖ ហើយបន្ទាប់មកទៀត ឆ្នាំប៉ុន្មានទៀត ដែលសម័យលន់ នល់?

ឆ្លង ៖ មកឆ្នាំលន់ នល់ ៧៥ ។

ធានី ៖ ៧៥ ឬ៧០?

ឆ្លង ៖ ៧៥ ។

ធានី ៖ ចុះសម័យខ្មែរក្រហម៧០ប៉ុន្មាន?

ឆ្លង ៖ អូ! តាំងពី៥០ប៉ុន្មានខ្មែរក្រហម អឺ!ខ្មែរក្រហមចូលមក៧០នេះឯង មក៧០នោះកើតហើយ ។

ធានី ៖ ចឹងសម័យប៉ុន្មានបានមានលន់ នល់ ៧០ ឬ៧៥?

ឆ្លង ៖ សម័យ៧៥ ។

ធានី ៖ ៧០អ៊ំ?

ឆ្លង ៖ បាទ! សម័យ៧៥កើតឥស្សរៈ អឺ!កើតសម័យឥស្សរៈកើតលន់ នល់ ។ កាលលន់ នល់រដ្ឋប្រហារមើល៧៥ការជម្លៀសសម្តេចតា ។

ធានី ៖ ចុះសម័យខ្មែរក្រហមពេលណា បើ៧៥អ៊ំថាកើតលន់ នល់ រដ្ឋប្រហារទម្លាក់សម្តេច?

ឆ្លង ៖ នែក! មុននោះ មុន៧៥ហ្នឹងឯងសម័យឥស្សរៈ ។

ធានី ៖ ចឹងមុនដំបូងខ្មែរក្រហមចេញពីឥស្សរៈ ។ ហើយបានខ្មែរក្រហម?

ឆ្លង ៖ បាទ! មកពីឥស្សរៈមកបានខ្មែរក្រហម វាជាប់គ្នាជាមួយ ។

ធានី ៖ ជាប់គ្នាជាមួយ ចឹងឥស្សរៈហ្នឹងក្លាយចឹង?

ឆ្លង ៖ បាទ!

ធានី ៖ ចឹងឥស្សរៈហ្នឹងកើតតាំងពីមុន១៩៧៣ទៅទៀត?

ឆ្លង ៖ បាទ! ដល់មកលន់ នល់នេះវាចេញរូបរាងមកហើយ ចេញរូបរាងពីឥស្សរៈមក ។

ធានី ៖ ចឹងលន់ នល់ ព្រោះសម័យលន់ នល់ ៧៥ហ្នឹងគេបែកលន់ នល់ហើយហ្នឹង គេសម្លាប់ចាប់ផ្ដើមសម្លាប់លន់ នល់ ហើយខ្មែរក្រហមកាន់កាប់?

ឆ្លង ៖ បើចេញកាលនោះ ៧៥ហ្នឹងរដ្ឋប្រហារលន់ នល់រត់ទៅរកអាមេរិច ។

ធានី ៖ ហ្នឹងហើយ ៧៥ ។ ហើយបន្ទាប់ពី៧៥មកបានខ្មែរក្រហមឡើង?

ឆ្លង ៖ បាទ! ខ្មែរក្រហមហើយបានឡើង ។

ធានី ៖ ខ្មែរក្រហមឡើងមក កាលហ្នឹងនៅភូមិអ៊ំមានប្រជាជនថ្មីមកនៅទេ?

ឆ្លង ៖ មានមកនៅនេះចាប់ជម្លៀសមកពីភ្នំពេញ មកនៅភូមិមកហើយខ្មែរក្រហម មកពីក្រុងភ្នំពេញ

ធានី ៖ មកភូមិហ្នឹងធ្វើអី?

ឆ្លង ៖ បាទ!

ធានី ៖ មករស់នៅភូមិហ្នឹងធ្វើអី?

ឆ្លង ៖ មកនៅភូមិផ្ដាំនេះ កាលឥស្សរៈនែក!ខ្មែរក្រហមនៅពេញគ្រប់តែក្រុមឲ្យបាយឲ្យទឹកឲ្យស្អីនេះ យើងកាន់ពួកខ្មែរក្រហមយើង ។

ធានី ៖ ហើយចឹបានពួកគាត់មកនៅហ្នឹងវិញ គាត់ម៉េចអត់ទៅនៅភ្នំពេញ?

ឆ្លង ៖ នែក!អង្គការគេជម្លៀសមក អង្គការឥស្សរៈ អឺ!អង្គការខ្មែរក្រហមនោះណា ជម្លៀសមកគេជម្លៀសចេញចូលមកពីខាងនេះ មកពីកើតនេះ ចេញមកពីយើងខេត្តសៀមរាប ។

ធានី ៖ ហើយភាគច្រើន គាត់មកពីស្រុកភូមិណាវិញ?

ឆ្លង ៖ ច្រើននៅភ្នំពេញ ។

ធានី ៖ អ្នកនៅភ្នំពេញម៉ែង?

ឆ្លង ៖ បាទ! អ្នកភ្នំពេញ ខាងភ្នំពេញ ។

ធានី ៖ អ៊ំស្គាល់ពួកគាត់ខ្លះទេ អ្នកខាងភ្នំពេញ?

ឆួង ៖ ចេះដែលនៅនេះ ដែលគាត់មានប្រាក់ ខ្មោចយាយអី នោះប្ដីគាត់ធំ គាត់មកមាន...ដឹកមាស ប្រាក់មក....អន្ទរម៉ាកំប៉ុងមាសម៉ាតំឡឹង ។

ធានី ៖ ស្គាល់គាត់ទេ?

ឆួង ៖ ឈ្មោះយាយឌីៗ នៅជ្រុងនេះ ខាងជាប់នេះផ្ទះតា....។

ធានី ៖ ហើយគ្រួសារគាត់ធ្វើអីអឹងដឹងទេ?

ឆួង ៖ ធ្វើ គ្រួសារគាត់ថាពាក់សក្តិ៥ យាយឌី គាត់....ធំដំបងដូចចិន ប្ដីពាក់សក្តិ៥ ។

ធានី ៖ អឹងដឹងសព្វថ្ងៃ គាត់នៅរស់ទេ?

ឆួង ៖ បាទ!

ធានី ៖ សព្វថ្ងៃយាយឌីគាត់នៅរស់ទេ?

ឆួង ៖ អត់ទេ ដល់នេះទៅគេទៅវិញទៅៗគាត់បែក គេហៅឲ្យចូលហើយ គាត់ចូលត្រឡប់ទៅវិញ ទៅផ្ទះវិញ ។

ធានី ៖ ចុះអឹកាលសម័យខ្មែរក្រហមអឹធ្វើអី?

ឆួង ៖ អត់ធ្វើអីទេ គេឲ្យវាស់តែ តំរង់ដីតែដី ។

ធានី ៖ តំរង់ដី?

ឆួង ៖ បាទ! តំរង់ទំនប់ តំរង់ប្រឡាយឲ្យដឹក ភ្លឺស្រែ គេឲ្យខ្ញុំតំរង់ ។

ធានី ៖ ខាងណាគេអ្នកឲ្យអឹតំរង់ហ្នឹង?

ឆួង ៖ ខាងចៅហ្វាយស្រុក ។

ធានី ៖ ចៅហ្វាយស្រុកហ្នឹងឈ្មោះអីគេ?

ឆួង ៖ ចៅហ្វាយស្រុកឈ្មោះតាហួត ចៅហ្វាយស្រុកខន ។

ធានី ៖ តាហួត ហើយខនហ្នឹងស្រី ប្រុស?

ឆួង ៖ នែក!ហួតប្រុសចៅហ្វាយស្រុក ។

ធានី ៖ ខន?

ឆួង ៖ ខន ប្រុស ។

ធានី ៖ ខនហ្នឹង ពីរនាក់ហ្នឹងមួយណាធំ?

ឆួង ៖ បាទ!

ធានី ៖ ពីរនាក់ហ្នឹងមួយណាធំ?

ឆួង ៖ វាអាបើគេចាប់តានេះបានមកឡើងខន ឡើងចៅហ្វាយស្រុកខន ។

ធានី : ដំបូងតាហួតប្រធានចៅហ្វាយស្រុក?

ឆ្លូង : តាហួត បាទ! ។

ធានី : បន្ទាប់មកទៀត ខនបន្ត?

ឆ្លូង : ខន ។

ធានី : ចឹងតាហួតត្រូវគេចាប់បាត់ហើយ?

ឆ្លូង : ចាប់រួច បានឡើងខនៗ បានដល់ខាងនារី ។

ធានី : នារីអីគេ?

ឆ្លូង : ឈ្មោះនែក នឿម យើងហៅអីហៅចៅសង្កាត់ៗ នឿម ។

ធានី : ឈ្មោះអីគេ នឿម?

ឆ្លូង : នឿម ។

ធានី : អីគេអ៊ំនិយាយមិញនឿម?

ឆ្លូង : អឺ! នឿមចៅសង្កាត់នៅនោះ ។

ធានី : នៅសហករណ៍យើងហ្នឹងអ៊ំ?

ឆ្លូង : បាទ! ប្រធានសហករណ៍ ។

ធានី : ប្រធានសហករណ៍ផ្តាំហ្នឹងឈ្មោះនឿម?

ឆ្លូង : បាទ! ប្រធានសហករណ៍ផង មេឃុំផង ធ្វើនៅនោះទាំងអស់ ហើយបានតាហួតៗមកបានខន មកពីខនមក នេះបាននាងសារី ។

ធានី : សារីហ្នឹង?

ឆ្លូង : សារីប្រធានសហករណ៍ បានពួកហ្នឹង ។

ធានី : ចុះនឿម?

ឆ្លូង : នឿម ងាប់បាត់ហើយ ។

ធានី : នឿមមេឃុំ?

ឆ្លូង : នោះហើយប្រធានសហករណ៍ ។

ធានី : ចឹងសារីមុន ឬនឿមមុន?

ឆ្លូង : នែក! នឿមមុនគេបង្អស់ ។

ធានី : បន្ទាប់ពីនឿមត្រូវគេចាប់ខ្លួនហើយបានសារីឡើង?

ឆ្លូង : មិនមែនទេ តាហួតនោះហើយ ចាប់តាហួតទៅខន ពីខនមកដល់សព្វថ្ងៃបានដល់សារី នារី ។

ធានី ៖ ចឹងសារីហ្នឹងបន្ទាប់ចៅហ្វាយស្រុកដែរ?

ធ្លូង ៖ បាទ! នោះហើយមិនថា...។

ធានី ៖ ស្រី អ៊ំស្រី?

ធ្លូង ៖ ស្រីៗ ដឹងមកពីណា។

ធានី ៖ ចឹងអ៊ំធ្វើអ្នកតំរង់ភ្លីស្រែហ្នឹងតាំងពីតាហ្លួតម៉េះ?

ធ្លូង ៖ តាំងពីតាហ្លួត។

ធានី ៖ កាចទេ អ៊ំ?

ធ្លូង ៖ អូ! មកដល់តាខន ចុះបើខ្ញុំតំរង់នោះ។

ធានី ៖ នៅណាវិញ?

ធ្លូង ៖ តំរង់ប៉ោយចារ ប្រាសាទប្រាំ បៀតព្រះនេត្រព្រះណា ត្រពាំងថ្ម។

ធានី ៖ អ៊ំនៅត្រពាំងថ្មដែរ តំរង់ក្បែរ?

ធ្លូង ៖ ទេ! មិនបានទេខាងនោះ អានេះគេខាងភ្លីស្រែ អាខាងអានេះគេមានអ្នកផ្សេង។

ធានី ៖ អ៊ំដឹងដែរ?

ធ្លូង ៖ មិនបានដឹងទេ មិនស្គាល់ទេ ប៉ុនដឹងគាត់ទៅនៅដើរបៀតនោះក៏ដើរទៅមើលគេលេងៗនោះហើយតាមនេះ។

ធានី ៖ ម៉េចដែរដើរមើលគេយ៉ាងម៉េច?

ធ្លូង ៖ មើលគេពេលបៀតសម្រាលម្តងៗទៅលេងនឹងចៅ គេហៅឲ្យទៅមើលត្រពាំងថ្មនោះណា ដើរខ្វាត់ខ្វែងៗ នោះឯងបានចូលមកដល់សព្វថ្ងៃនៅបានសុខសាន្ត សម្តេចហេងសំរិន សម្តេចជាស៊ីម សម្តេចតេជោហ៊ុន សែន ក៏បានរៀបចំមក។

ធានី ៖ ចឹងកាលពេលអ៊ំនៅធ្វើជាអ្នកតំរង់ភ្លីស្រែហ្នឹង គេឲ្យតំរង់យ៉ាងម៉េច?

ធ្លូង ៖ តំរង់ប្រព័ន្ធភ្លីស្រែយើង អាបិទភ្លី។

ធានី ៖ បិទភ្លី?

ធ្លូង ៖ អឺ! បិទភ្លីតំរង់មិនបានបោះបង្គោលឲ្យគេទៅ អាអ្នកលើកចេះតែលើទៅ ខ្ញុំអ្នកតំរង់គ្នា២នាក់ ៣នាក់។

ធានី ៖ ៣នាក់?

ធ្លូង ៖ អឺ! ៣នាក់។

ធានី ៖ អ្នកណាគេខ្លះអ៊ំកាលហ្នឹង?

ឆ្លង : តាជូន ឈ្មោះគាត់តាជូនមួយ ។

ធានី : និងអ្នកណាគេទៀតអ៊ី?

ឆ្លង : នែក! នៅនោះឈ្មោះតាហួន ។

ធានី : តាហួន?

ឆ្លង : បាទ! នៅភូមិតាត្រៃ ។

ធានី : ៣នាក់ហ្នឹងជាអ្នកធ្វើការជាមួយអ៊ីដែរ?

ឆ្លង : បាទ! ធ្វើការជាមួយគ្នា ។

ធានី : តំរង់ភ្លឺស្រែហ្នឹងនៅកន្លែងណាខ្លះ?

ឆ្លង : បាទ!

ធានី : នៅណានៅភូមិនេះ?

ឆ្លង : តំរង់នឹងភូមិនេះហើយ តំរង់ភូមិ ។

ធានី : ភូមិថ្កាំ?

ឆ្លង : ភូមិថ្កាំ ទៅខាងភូមិអូរ ។

ធានី : តែនៅក្នុងឃុំថ្កាំដែរ?

ឆ្លង : ឃុំថ្កាំនេះ ដើរឆ្ងាយ បានឈប់តំរង់នេះរួចហើយក៏គេឲ្យទៅជួយតំរង់ប្រព័ន្ធភ្លឺស្រែដូចគ្នា ខាងប៉ោយចារ រំចេក ឲ្យទៅនៅនោះ ។

ធានី : ហើយតំរង់ហ្នឹង គ្រាន់តែយើងវាស់បង្គោលហើយឲ្យគេអ្នកលើកៗទៅ?

ឆ្លង : បោះ បានបោះ ។

ធានី : ចុះតំរង់ហ្នឹងប៉ុន្មានម៉ែត្រៗម៉ាភ្លឺអីចឹង មានគេវាស់ចឹងអត់ធ្វើម៉េចឲ្យតែត្រង់ចឹង ឬម៉េច?

ឆ្លង : គេមើល តំរង់ ខ្លះណាតំរង់បានត្រង់ទៅចេះហើយបោះបង្គោល ។

ធានី : ដឹងប៉ុន្មានម៉ែត្រៗ?

ឆ្លង : ២ម៉ែត្របង្គោកមួយៗ អាតំរង់ឈរនៅកណ្ដាល បោះអានេះដាក់ទៅ បោះតំរង់គេរួចជួយ លើក ដឹងអ្នកណាអ្នកលើក អត់មានដឹងអីលីង ។

ធានី : ចឹងអ៊ីកាលហ្នឹងអ៊ីមានស្ការអីអត់ពេលធ្វើតំរង់?

ឆ្លង : អត់ទេ អត់មានអី ។

ធានី : ចុះមានប្រធានគេ ប្រធានតំរង់ហ្នឹង?

ឆ្លង : ប្រធានគាត់នៅលើ គណៈស្រុកនោះ ។

ធានី : គណៈស្រុកហ្នឹងឈ្មោះតាហួតហ្នឹង?

ឆ្លូង : បាទ! តាហួតហ្នឹង ។

ធានី : ស្អីគេហួត?

ឆ្លូង : មិនចាំ មិនស្គាល់អីហួត ។

ធានី : ហើយកាលហ្នឹងនៅយើងតំបន់ប៉ុន្មានអ៊ំដឹងទេ?

ឆ្លូង : តំបន់៥ ។

ធានី : តំបន់៥ ?

ឆ្លូង : បាទ! នៅតំបន់៥ ។

ធានី : គណៈស្រុកឈ្មោះហួត?

ឆ្លូង : បាទៗ ឈ្មោះហួត ។

ធានី : បន្ទាប់ពីតាហួតមក បានឈ្មោះខនឡើងបន្ត?

ឆ្លូង : បាទ! ឡើងបន្ត ។

ធានី : ហើយឈ្មោះសារី?

ឆ្លូង : បន្តមកបានសារី បានបែកបាក់ ។

ធានី : ចៅហ្វាយស្រុក តំបន់៥ តាហួត?

ឆ្លូង : តាហួតហ្នឹងហើយ ។

ធានី : ចឹងតាហួតជាគណៈតំបន់?

ឆ្លូង : ទេ! មិនដឹងគណៈតំបន់ មិនដឹង ប៉ុនគេថាចៅហ្វាយស្រុកៗ ដឹងថាចៅហ្វាយស្រុកប៉ុននោះ ។

ធានី : ចៅហ្វាយស្រុកអីគេ អ៊ំ?

ឆ្លូង : ចៅហ្វាយស្រុកគឺតាហួតហ្នឹង ។

ធានី : មិនមែនទេ ចង់ថាដូចយើងឥឡូវចៅហ្វាយស្រុកមានឈ្មោះគេ ដល់ពេលខេត្តហ្នឹងវាមាន ទៀត តែនៅសម័យខ្មែរក្រហមមានជាតំបន់វិញ?

ឆ្លូង : បាទ!

ធានី : មានតំបន់ហើយស្រុក?

ឆ្លូង : បាទ!តំបន់គេផ្សេង តំបន់ខាងលោកស្ដីអើយ! យីម ខ្ញុំភ្លេចទៅគេអ្នកធំ ដល់ធំទៅចុះឯងដឹង ត្រឹមតែតូចៗនេះ ធំ ។

ធានី : ចឹងអ៊ំដឹងភូមិភាគហ្នឹងភូមិភាគអី?

ឆ្លង ៖ ភូមិភាគ៥ ។

ធានី ៖ ភូមិភាគ?

ឆ្លង ៖ បាទ! ភូមិភាគ៥ ពាយ័ព្យកាលហ្នឹង ។

ធានី ៖ ភូមិភាគពាយ័ព្យហ្នឹងនៅក្នុងតំបន់ហ្នឹង នៅក្នុងតំបន់ហ្នឹងហៅតំបន់៥?

ឆ្លង ៖ បាទ! តំបន់៥ ។

ធានី ៖ ហើយអ្នកណាគេប្រធាន តំបន់៥?តាញឹម ឬយឹម?

ឆ្លង ៖ តំបន់នោះៗហើយដឹងថាយឹមៗ លោកស្តីយឹមនោះ យឹមចេះឯង ។

ធានី ៖ តាញឹម ឬក៏យឹម?

ឆ្លង ៖ ញឹមៗ ឈ្មោះញឹមចេះឯង ។

ធានី ៖ តាញឹមហ្នឹងជាប្រធានភូមិភាគ?

ឆ្លង ៖ ប្រធានភូមិភាគ ប្រធានតំបន់ធំ ម៉ា ។

ធានី ៖ ចាំ!ម៉ាគ្រប់គ្រងគឺតាញឹម?

ឆ្លង ៖ បាទ! តានោះឯងជាប្រធានធំ ។

ធានី ៖ តាញឹម?

ឆ្លង ៖ បាទ!

ធានី ៖ ហើយចុះបន្ទាប់មកប្រធានតំបន់តាហួត?

ឆ្លង ៖ បាទ! មកដល់គណៈស្រុក ។

ធានី ៖ គណៈស្រុកតាហួត?

ឆ្លង ៖ បាទ! តាហួត ។

ធានី ៖ ចុះគណៈតំបន់?

ឆ្លង ៖ គណៈតំបន់មិនស្គាល់ទេ មិនបានស្គាល់ទេ ។

ធានី ៖ ប៉ុន្តែដឹងថាតំបន់ហ្នឹងតំបន់៥ចឹង?

ឆ្លង ៖ បាទ! តំបន់៥ៗហ្នឹងហើយកាចជាងគេ ។

ធានី ៖ ឈ្មោះអីគេអ៊ំដឹងទេ?

ឆ្លង ៖ ដែលម៉ាតំបន់ទាំងអស់ហ្នឹងដែលគេធ្វើបាប ដូចថាកាន់នេះឯង ។

ធានី ៖ ដឹងគណៈតំបន់ឈ្មោះអីអ៊ំ?

ឆ្លង ៖ មិនស្គាល់ មិនចាំ ។

ធានី ៖ ចុះដឹងខាងក្រោយអ្នកដឹកនាំលើកទំនប់ត្រពាំងថ្មឈ្មោះអី?

ឆ្លង ៖ វាអស់ត្រឹមនោះៗចូលមកវារត់រប៉ាត់រប៉ាយអស់ ។

ធានី ៖ ហ្នឹងអ៊ំដឹងអ្នកណាគេ?

ឆ្លង ៖ មិនស្គាល់ ។ តែដល់បែកចូលបានយួនចូលមកដល់ ហើយក៏អស់គ្នារប៉ាត់រអស់រលីង ។

ធានី ៖ ចុះអ៊ំដែលធ្លាប់ឮយាយថែម?

ឆ្លង ៖ មានឮណាយាយថែមដឹងនៅណា ឮគេថាយាយថែមៗមេទ័ពមិនដែលមកនេះទេ ។

ធានី ៖ អូ!ធ្លាប់ឮគេនិយាយថាយាយថែម មេទ័ពដែរ?

ឆ្លង ៖ បាទ! យាយថែម ។

ធានី ៖ មេទ័ពអីគេ?

ឆ្លង ៖ មេទ័ពកាលនោះ គាត់ចុះមកពីឥស្សរៈចូលមកដល់ខ្មែរក្រហមមក គេបានលោកអ៊ីអាមេ ឥស្សរៈអាធំដែលគេបាញ់ងាប់នឹង ពួកបារាំងបាញ់ហ្នឹងស្វាយសនេះ ឈ្មោះមេអីហើយ ឈ្មោះលោកអីហើយអត់ ភ្លេចហើយមិនចាំ ។

ធានី ៖ ប៉ុន្តែយាយថែមហ្នឹង គាត់អ្នកគ្រប់គ្រងនៅហ្នឹងយើងដែល ខាងមេទ័ព?

ឆ្លង ៖ នៅម៉ាដួរគាត់ខាងនេះ គាត់មិនថានៅនេះទេ គាត់នៅម៉ាដួរយើងដីតំបន់នេះ តំបន់៥នេះ ។

ធានី ៖ ចា៎! យាយថែមនៅតំបន់៥ហ្នឹង?

ឆ្លង ៖ បាទ!នៅនោះ ។

ធានី ៖ តែកាលគាត់មកៗពេលណា អ៊ំដឹងទេ?

ឆ្លង ៖ មិនដឹងដែរ មិនដឹង ។

ធានី ៖ តែកាលហ្នឹងគឺងអត់ ពេលយាយថែមក ឬក៏ធូរជាង?

ឆ្លង ៖ យាយថែម គាត់មិនសូវដែលបានមកនេះទេ គាត់ខាងៗទាហាន គាត់អ្នកខាងទាហាន ឮតែគេនិយាយថាជិះតែសេះ ។

ធានី ៖ យាយថែមខាងទាហាន?

ឆ្លង ៖ ខាងទាហាន ។

ធានី ៖ តែតាហួតហ្នឹងខាងប្រជាជន?

ឆ្លង ៖ បាទ! ខាងប្រជាជន ។

ធានី ៖ ចុះកាលពេកលតាហួតនៅ យាយថែមមកនៅ?

ឆ្លង ៖ នៅវាមានមកនៅនោះ ។

ធានី ៖ គាត់មក?

ឆ្នួង ៖ គាត់បែកចោលមកខាងនេះ គាត់ច្រើននៅតែខាងនោះ ច្រើននៅខុត្តរ នៅខាង...នៅខាងនោះ ដែរ ។

ធានី ៖ ចឹងតាអត់ដឹងដែរ?

ឆ្នួង ៖ បាទ!

ធានី ៖ អត់ដឹងដែរ?

ឆ្នួង ៖ នោះហើយមិនដឹងមិនស្គាល់ ។

ធានី ៖ ចឹងលោកតានៅកាលហ្នឹងយាហួតហ្នឹង អ្នកបញ្ជាឲ្យធ្វើស្រែធ្វើភ្លឺហ្នឹង ឬក៏មានអ្នកណាផ្សេងទៀត ក្រោមហ្នឹង?

ឆ្នួង ៖ គាត់ហ្នឹងហើយ ។

ធានី ៖ គាត់ហ្នឹង?

ឆ្នួង ៖ បាទ! គាត់ហ្នឹងអ្នកបញ្ជាឲ្យវាស់ ឲ្យអី ។

ធានី ៖ ធ្វើអី?

ឆ្នួង ៖ ឲ្យតំរង់ អាថ្នល់នេះ ខ្ញុំអ្នកតំរង់ នេះអាថ្នល់ពីកើតនេះ តំរង់ឲ្យដាច់ដល់ទៅអូរ ដាច់ដល់អីទៅនោះ ហើយអាទំនប់ប្រឡាយនេះក៏ខ្ញុំអ្នកតំរង់បិទភ្លឺមក ។ ដល់ចឹងមាននាទីអីទៅប្រាប់គេ មាននាទីតំរង់ប៉ុននោះ មិនបានធ្វើអីគេ ។

ធានី ៖ ចឹងលោកតាចុះពេលក្រោយពីគេតំរង់ហ្នឹង ។ តំរង់ហ្នឹងគេច្រើនធ្វើខែវស្សាមែនទេលោកតា?

ឆ្នួង ៖ ខែវស្សា ។

ធានី ៖ ចុះខែប្រាំងយើងធ្វើ ចុះខែវស្សាធ្វើអីវិញ?

ឆ្នួង ៖ ខែវស្សានៅតែស្ទៀមចឹង ដល់តែគេឲ្យឈប់អានោះគេឲ្យទៅនៅចំការនៅនេះដាំឪឡឹក ដាំពោតអីនោះ គេឲ្យនៅដាំនោះចំការឪឡឹក ហើយនឹងស្រោចដាំថ្នាំនៅសូភីនេះ ។ ម៉ាថ្ងៃពីនោះមកឲ្យធ្វើដី។ខែនេះឲ្យខែវស្សាឲ្យស្រោចដីមួយថ្ងៃ១០០អំរែក ។ ឲ្យស្រោចដី កាត់ដីដាក់ចំបើងដាក់អី កាប់កន្ទ្រានខែត្រដាក់ខែវស្សាឲ្យធ្វើស្រោចដី ម៉ាថ្ងៃ១០០អំរែកដាងនោះ ។ ឈប់ពីអស់អានោះទៅដាំថ្នាំខាងនោះ ។

ធានី ៖ ដាំថ្នាំអីគេ ថ្នាំជក់?

ឆ្នួង ៖ ថ្នាំជក់យើង ។

ធានី ៖ ថ្នាំជក់នៅភូមិឃុំអីគេ?

ឆ្នួន : នៅអាខាងកើតវាំនេះ ។

ធានី : អូ! នៅភូមិផ្អាំយើងនេះ?

ឆ្នួន : ហ្នឹងហើយភូមិផ្អាំនេះឯង ។

ធានី : ស្មានទៅភូមិណាផ្សេង?

ឆ្នួន : ទេ! នៅនេះ បើទៅតំរង់ដីបានចូលទៅភូមិអូរឯកើតនោះ ។

ធានី : ចុះលោកតាខាងប៉ុំព៉ា ខាងអីគេមកវ៉ៃសំរុកអីដែរ នៅភូមិយើង?

ឆ្នួន : ណា៎?

ធានី : ថាភូមិផ្អាំហ្នឹងជាសមរភូមិផង?

ឆ្នួន : ប៉ុំពៅនិងខ្មែរក្រហម មកវ៉ៃសំរុក កាលយួនមកនៅក៏វ៉ៃគ្រាន់តែយួនដែលចូលមកវ៉ៃ គ្រាន់យួនដែលចូលមកនៅបានហើយ វ៉ៃ ជិត៨៣ដង អាកាណុងមកពីនោះក៏បាញ់តំរង់ដាក់មក ។

ធានី : ចឹងកន្លែងយើងនេះមានប្រជាជននៅដែល ពេលដែលមានសង្គ្រាមហ្នឹង?

ឆ្នួន : នៅ បាទ! នៅតាមនេះហើយ ប៉ុន្តែដាំដើមស្រូវអត់សូវដែរអី មិនសូវដែរអីទេ ។

ធានី : គេបាញ់គ្នាទៅ យើងនៅក្នុងផ្ទះទៅ?

ឆ្នួន : នៅអី បើរត់ចូលត្រង់សេរនោះអាគ្រាប់ដាក់ជីកត្រង់សេររួចក៏ដាក់ លើកសសរនេះកំណាត់ចេះដាក់នៅមុខ គេចូលមកពីនោះក៏បាញ់មក ឯងកំពុងក្រាបអាចៅយំដងអីដង អាគ្រាប់ផ្ទុះចូលមកឆាបក្បាលឆេះអាអស់ត្រង់សេរទៅទម្រាំរត់បាន ។ ហើយដល់បាញ់ៗនៅវាធ្លាក់ក៏មិនសូវដែរអីទេ អាក្នុង៤០ក្នុងអាមកម្តង២-៣ ។ ក៏មិនដែលមានអ្នកណាងាប់អីទេ មានងាប់ដែរ មានងាប់ ។ បាទ! វាវេទនាណាស់ភូមិនេះ ។

ធានី : រត់ចុះរត់ឡើង?

ឆ្នួន : បាទ!

ធានី : ចុះបានអីហូប លោកតាបើសង្គ្រាមចុះឡើងចឹង?

ឆ្នួន : អូ! ចៅអើយ ជីកតែអាកូនអន្ទរបុកដៃកិនដៃតិចចេះតែចង់ទៅមានអី មានស្អីបានអីហូបទេ វេទនាដែលកើតសង្គ្រាម ដែលជុតភូមិនេះទេ ។ រងទុក្ខណាស់វាបានច្រើន...ដល់បានមកដល់ សព្វថ្ងៃនេះ បានសុខបានសាន្តហើយស្រួល ។

ធានី : លោកតាៗមានឈ្មោះអីដែរ?

ឆ្នួន : ខ្ញុំនេត ឆ្នួន ។

ធានី : នេត ឆ្នួ?

ឆ្លង ៖ ឆ្លង ។

ធានី ៖ ឆ្នាំហ្នឹងអាយុប៉ុន្មានលោកតា?

ឆ្លង ៖ ៧៨ ។

ធានី ៖ លោកតាមានស្រុកកំណើតនៅណាវិញ?

ឆ្លង ៖ នៅនេះហើយ ។

ធានី ៖ កំណើតនៅភូមិឃុំអីដែរ?

ឆ្លង ៖ ឃុំកំណើតខ្ញុំនៅយាងវេណ ។

ធានី ៖ ចឹងលោកតានៅស្រុកកំណើតនៅភូមិអីគេ?

ឆ្លង ៖ យាងវេណ ។

ធានី ៖ យាងវេណ ឃុំអីដែរ?

ឆ្លង ៖ ឃុំនេះហើយ ។

ធានី ៖ ឃុំផ្គាំ?

ឆ្លង ៖ បាទ! ឃុំផ្គាំ ។

ធានី ៖ ដល់ពេលស្រុក?

ឆ្លង ៖ បួសមក បានសឹកទៅក៏បានគ្រួសារនៅនេះ ក៏នៅជាប់នេះរហូត ។ ស្រុកកំណើតនៅម៉ាទិត.... ទៅខាងលិចនេះៗ ។

ធានី ៖ ចឹងលោកតារាល់ថ្ងៃរស់នៅភូមិអីគេដែរ?

ឆ្លង ៖ រស់នៅភូមិផ្គាំ ។

ធានី ៖ ភូមិផ្គាំ ឃុំ?

ឆ្លង ៖ ឃុំផ្គាំ ។

ធានី ៖ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ?

ឆ្លង ៖ ស្រុកស្វាយចេក ខេត្តស្វាយចេក បាទ! ខេត្តបន្ទាយមានជ័យ ។

ធានី ៖ លោកតារៀបគ្រួសារឆ្នាំប៉ុន្មាន?

ឆ្លង ៖ រកបង់មិនឃើញ មិនបានចំណាំទេ វាដូចរវាងពីខែឆ្នាំ រវាង៥០ ៥៨ ។

ធានី ៖ ៥៨ក្រោយឯករាជ្យហើយ លោកតា?

ឆ្លង ៖ ខ្ញុំកើត១៩៣៣ ខ្ញុំបួស ។

ធានី ៖ អូ!លោកតាកើត១៩៣៣ ។ ខ្ញុំបួសកាលនោះ ។

ឆ្លង ៖ ចាំ! ដល់៩៨វៀបគ្រួសារ អេ!លោកតា?

ធានី ៖ នែក! អ្នកណា ឈ្មោះប្រពន្ធលោកតា?

ឆ្លង ៖ កៀ្ហយយាំង ។

ធានី ៖ កៀ្ហយ?

ឆ្លង ៖ កៀ្ហយ យាំ ។

ធានី ៖ គាត់នៅរស់ទេ?

ឆ្លង ៖ ខូចហើយ ។ ខូចពេលណាទៅ ខូចបានប្រហែល៣០ឆ្នាំជាង ។

ធានី ៖ ចឹងគាត់ស្លាន់ពេលណា ស្លាប់ដោយសារអីលោកតា?

ឆ្លង ៖ ជម្ងឺរោគា ។

ធានី ៖ នៅសម័យខ្មែរក្រហមយើង មុនបែកខ្មែរក្រហម?

ឆ្លង ៖ នៅសម័យយួនរត់ បាទ!នៅនេះកើតពេទ្យកើតអីនៅបានអស់ហើយ ។

ធានី ៖ អឺ!គ្រប់ភូមិអស់សង្រ្គាស ។

ឆ្លង ៖ អស់ហើយ វាអស់កើតនៅសង្រ្គាម ទៅដេកនៅ....ដេកពេទ្យក៏មិនមានថ្នាំមានសង្កូវអីបានច្រើន ។

ធានី ៖ ចុះលោកតាមានកូនចៅប៉ុន្មាននាក់ដែរ?

ឆ្លង ៖ ចៅ៦នាក់ ។

ធានី ៖ កូន?

ឆ្លង ៖ អឺ!កូន៦នាក់ ។

ធានី ៖ កូន៦នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ឆ្លង ៖ ស្រី៣ ប្រុស៣ ។

ធានី ៖ នៅរស់ទាំង៣ទេ នៅរស់ទាំងអស់?

ឆ្លង ៖ នៅរស់ទាំងអស់ ។

ធានី ៖ នៅរស់ទាំងអស់?

ឆ្លង ៖ នៅ ។

ធានី ៖ ឪពុកលោកតាឈ្មោះអីគេ?

ឆ្លង ៖ ឈ្មោះ នេត សារ៉ាំ ។

ធានី ៖ ម្តាយ?

ឆ្លង ៖ ម្ដាយ ជា អែល ។

ធានី ៖ គាត់នៅរស់ឬក៏?

ឆ្លង ៖ ខូចអស់ហើយ ។

ធានី ៖ ខូចសម័យមុន?

ឆ្លង ៖ បាទ! ខូចមុនសម័យ ។

ធានី ៖ ជា ឯង?

ឆ្លង ៖ អែល ជា អែល ។

ធានី ៖ ចាម ឬក៏ខ្មែរ?

ឆ្លង ៖ ខ្មែរ ។

ធានី ៖ ខ្មែរទាំងអស់?

ឆ្លង ៖ បាទ! ខ្មែរ ។

ធានី ៖ ឈ្មោះដូចអ៊ីស្លាម?

ឆ្លង ៖ ខ្ញុំអ្នកជាតិនេះតើ ជាតិសុរិន្ទ ។

ធានី ៖ លោកតាជាសុរិន្ទ?

ឆ្លង ៖ មិនមែនណា តាខ្ញុំនៅសុរិន្ទស្រុកថៃ ។

ធានី ៖ ចា៎! សុរិន្ទស្រុកថៃ ។ ចុះគ្រួសារលោកតា សុរិន្ទដែរអត់ទេ?

ធីតា ៖ ខ្មែរសុរិន្ទ?

ឆ្លង ៖ បាទ!ខ្មែរសុរិន្ទ ។ បាទ!ចុះមកនៅបានចៅ ។

ធានី ៖ ចុះលោកតាថាបួសរៀនហ្នឹង បួសពេលណា បួសឆ្នាំប៉ុន្មានចាំទេ?

ឆ្លង ៖ ឆ្នាំ ។

ធានី ៖ បួសនៅណាវិញ?

ឆ្លង ៖ អាយុនែក!១១ បួសណេន ៣៣ ។

ធានី ៖ ចឹងបួសពេលតាំងអាយុ១១ រហូតដល់អាយុ៣៣បានរៀបគ្រួសារ?

ឆ្លង ៖ បាទ! ដល់២៨ បានសឹក ។

ធានី ៖ អូ! រហូតដល់២៨ឆ្នាំបានសឹក?

ឆ្លង ៖ បាទ! ២៨ ។

ធានី ៖ សឹកហើយរៀបគ្រួសារ?

ធួង ៖ បាទ! បានគ្រួសារ ។

ធានី ៖ បួសនៅវត្តណាលោកតា?

ធួង ៖ វត្តផ្កាំយើងនេះ ។

ធានី ៖ ឈ្មោះអីប្រាសាទណាលោកតានិយាយមិញ?

ធួង ៖ វត្តកោះប្រាសាទភ្នំផ្កាំ ។

ធានី ៖ ហើយក្រោយពីបួសហើយបានលោកតារៀបគ្រួសារទៅ បានចូលសម័យខ្មែរក្រហមឥស្សរៈអីហ្នឹងលោកតា?

ធួង ៖ ចូលខ្មែរក្រហម បាទ!ខ្មែរក្រហមកើតឡើង ។

ធានី ៖ ចុះលោកតាយល់ថាពីសម័យមុន ហើយសម័យឥឡូវវាម៉េចដែរ?

ធួង ៖ អូ! ខុសគ្នាឆ្ងាយណាស់ ខុសពីសម័យដាន់ដើមណាស់ ។

ធានី ៖ ខុសយ៉ាងម៉េចលោកតា?

ធួង ៖ ដាន់ដើមធ្វើក្រោយលំបាក ។

ធានី ៖ លំបាក់យ៉ាងម៉េច?

ធួង ៖ កាលនោះមិនទាន់មានឡាន មិនទាន់មានកង់ តែកង់ ក៏មិនសូវមានទៀត មានតែដើរ ។ ខ្ញុំទៅនៅរៀននោះ ទៅនៅរៀនបាត់ដំបង់នោះក៏គេទៅតែដើរគ្មានឡានជិះទេ ទៅៗជិះឡានថ្នល់ជាតិយើងនោះដើរ ទៅនៅ ។

ធានី ៖ ចុះលោកតាដឹងថាភូមិយើងហ្នឹងកកើតឡើងតាំងពីពេលណាទេ?

ធួង ៖ យូរហើយនាង ដូចចូល២០០-៣០០ឆ្នាំ កើតមិនទាន់ ។

ធានី ៖ កើតយូរហើយ?

ធួង ៖ បាទ!

ធានី ៖ ហើយដឹងហេតុអីបានគេដាក់ឈ្មោះភូមិផ្កាំ?

ធួង ៖ ភូមិផ្កាំមានដើមផ្កាំ គេដាក់ អ្នកកំណើតៗកើតនេះបានអ្នកណាំតាវ ។

ធានី ៖ អ្នកណាំតាវហ្នឹងអ្នកខាងណា?

ធួង ៖ ដែលបានមកកើតនៅភូមិនេះ ។

ធានី ៖ អ្នកណាំតាវ អ្នកហ្នឹងគាត់មកពីណាវិញ?

ធួង ៖ មិនដឹងមកពីណាទេ កាលនោះគេផ្ដួលចោរ ។

ធានី ៖ ចោរ?

ឆ្លង ៖ ចោរគេរកចាប់ទៅនាំគ្នារត់បែកបាក់ទៅមកនៅនែក ។

ធានី ៖ ចឹងចោរច្រើន នៅហ្នឹង?

ឆ្លង ៖ មិនមែនចោរច្រើនទេ សម័យនោះមិនមានចោរច្រើន ចោរតិច ។

ធានី ៖ ចោរហ្នឹងចោរយ៉ាងម៉េច?

ឆ្លង ៖ ចោរលួចយើងធម្មតាទៅនេះ ប៉ុន្តែចោរនៅសម័យនោះលួចល្អណាស់ មិនដែលលួចហើយ
បាញ់សម្លាប់គ្នាដូចយើងសព្វថ្ងៃទេ ។ លួចបើថាលួចគឺថាបើវាមានគោគ្នាម៉ានឹម យកតែមួយ
មិនមានទាក់មានអីលោក គេលួចនៅក្នុងអនុគ្រោះ ។

ធានី ៖ ចាំ!ដូចថាយកតែមួយៗមិនយកទាំងអស់?

ឆ្លង ៖ យកតែមួយនេះណា មិនមានការផ្ដាច់យករបស់គ្នាហើយបាញ់ទៀតដូចយើងសព្វថ្ងៃទេ ។

ធានី ៖ ចឹងកាលមុនកន្លែងនេះព្រៃយ៉ាងម៉េចតា?

ឆ្លង ៖ ព្រៃ សុទ្ធតែខ្លានោះ ពីដើមមិញខ្លារមាំង ។

ធានី ៖ ចឹងចោរហ្នឹងមកពីភូមិខាងណាខ្លះណាំតាវ?

ឆ្លង ៖ មកពីខាងណាំតាវមក ។

ធានី ៖ ណាំតាវខាងណា ខាងថៃ?

ឆ្លង ៖ នេះនៅឯកើត ។

ធានី ៖ ភូមិណាំតាវ?

ឆ្លង ៖ នេះនៅខាងកើតភ្នំស្រុក នែក!ខាងជើងភ្នំស្រុក ។

ធានី ៖ ហើយចឹងចោរហ្នឹងមកពីភូមិណាំតាវហ្នឹង ក៏មកនេះដុំគ្នាចោរផ្សេងៗគ្នាមកជុំគ្នានៅនេះទៅ?

ឆ្លង ៖ នៅរួមគ្នាទៅ មិនមែនចោរទាំងអស់ទេ វាមាន ប៉ុនអាមកពីដើមកំណើតគឺ ។

ធានី ៖ ហើយចោរហ្នឹងមកនឹងធ្វើអី មកក្នុងព្រៃ?

ឆ្លង ៖ មកនៅដុនរត់ពួក កុំឲ្យគេរកចាប់ អាបង់កាត៥ផ្លូត់ បានរួចទៅនៅជាប់គ្នា... ។

ធានី ៖ ចឹងប្រមូលជុំគ្នានៅក្នុងព្រៃទៅកកើតជាភូមិទៅ?

ឆ្លង ៖ បាទ!

ធានី ៖ ចឹងកាលពីមុនកន្លែងហ្នឹងជាព្រៃទេ ប៉ុន្តែដល់ពេលមកនៅ?

ឆ្លង ៖ ព្រៃមកចំការធ្មើនេះ ធ្វើអីសុទ្ធតែខ្លាមកចាប់ដាក់...មកចាប់បានវាកាច់កបានវាក្រវាត់ទៅខាង
ក្រៅ តែវាចាប់មកហើយ អ្នកស្រុកអ្នកហ៊ាននេះទេ ពីដើមមិញសុទ្ធតែគេ ។

ធានី ៖ ចឹងបានន័យថាក្រោយមកទៀត មានសត្វព្រៃអីមកហ្នឹងដែរ?

ឆ្លង ៖ បាទ! អស់នៅ សព្វថ្ងៃក៏មាននៅ។

ធានី ៖ សព្វថ្ងៃហ្នឹងលោកតា?

ឆ្លង ៖ មានខ្លានៅ ប៉ុន្តែមិនដែល។

ធានី ៖ ព្រៃនៅខាងណាវិញ ព្រៃខាងណាបានមានខ្លាមក?

ឆ្លង ៖ លើភ្នំនេះ។

ធានី ៖ លើភ្នំនេះ?

ឆ្លង ៖ បាទ!

ធានី ៖ ភ្នំហ្នឹងហៅភ្នំអី?

ឆ្លង ៖ ហៅភ្នំផ្កាំ។

ធានី ៖ ភ្នំផ្កាំ?

ឆ្លង ៖ បាទ! នៅប៉ុន្តែវាមិនសូវឲ្យដែលឃើញទេ ម្តងៗពីដើមមិញឈ្លូស រមាំង ទន្សាយអីច្រើនណាស់ចៅ ពួកខ្ញុំនេះអ្នកដែលមានម្ហូបឲ្យហូប មានតែខ្សែរួចស្នូងដកអីហើយ មកនាំគ្នាឡើងភ្នំដេញជ្រូក ដេញទន្សាយ ដេញសំពោច។

ធានី ៖ តែឥឡូវរកបានទេតា ឥឡូវរកបានទេ ជ្រូក ទន្សាយ?

ឆ្លង ៖ បាទ! អស់ហើយ ចង់អស់ នៅសល់តិចណាស់មិនមានអ្នក១-២ សព្វថ្ងៃមានតែឈ្លូស ខ្លាមាន១មិនដឹងទៅណា ពីដើមមិញមានឃើញគន្លងដែរតើ សព្វថ្ងៃរត់ទៅនោះអស់ដឹងទៅអាព្រៃ ទ្រប់អាព្រៃធំនោះក៏គេទៅនៅអស់ទៀតក៏មានអ្នក អស់ហើយសព្វថ្ងៃបែកបាននៅទេ នៅអា ព្រៃធំគេហៅកើតជាស្រែជាស្រូវអស់ហើយព្រៃផ្តៅ។

ធានី ៖ ចឹងលោកតារាល់ថ្ងៃធ្វើអីដែរ?

ឆ្លង ៖ សព្វថ្ងៃធ្វើអី ធ្វើអាចារ្យវត្ត។

ធានី ៖ អាចារ្យវត្តណា?

ឆ្លង ៖ ខ្ញុំធ្វើតែសាលាធ្វើតែកុដិ។

ធានី ៖ អាចារ្យវត្តផ្កាំយើង?

ឆ្លង ៖ បាទ! នេះចៅជួយតាមើលប្រាក់ខ្វះទិញក្បឿង។

ធានី ៖ ចៅមកលេងលោកតា។

ឆ្លង ៖ និយាយលេងចៅអើយ។ ដែលមានខ្ញុំ...ធ្វើការក៏វាមិនដែលស្គាល់លោកអ្នកធំអ្នកណាអីទេ គាថាខ្ញុំគាត់ធ្វើអាចារ្យដូចគ្នា គ្រាន់គាត់វង្សខ្ញុំ។

ធានី ៖ ចឹងលោកតារាល់ថ្ងៃខ្ញុំធ្វើអាចារ្យដែរ?

ឆ្លង ៖ ធ្វើអាចារ្យ ។

ធានី ៖ ធ្វើស្រែចំការផង ធ្វើអាចារ្យផង?

ឆ្លង ៖ អឺ! ធ្វើអាចារ្យ ។

ធានី ៖ ខែបុណ្យខែទានយើងចូលវត្តទៅ?

ឆ្លង ៖ បាទ! ហ្នឹងហើយ ថ្ងៃណាថ្ងៃសីល១ ថ្ងៃ៨ថ្ងៃអីទៅសុំសីលទៅ ។

ធានី ៖ ចឹងលោកតាមានអីចង់សួរខ្ញុំវិញទេ?

ឆ្លង ៖ បាទ! មានអីទេចៅ ។

ធានី ៖ អត់ទេលោកតានោះ?

ឆ្លង ៖ បាទ!

ធានី ៖ ចឹងអរគុណលោកតា ។

ឆ្លង ៖ បាទ!

ធានី ៖ ចឹងលោកតាចៅសុំយកអ៊ីដែលលោកតាប្រាប់ខ្ញុំ ក៏ដូចជារឿងរ៉ាវដែលលោកតានិយាយមិញទាំងប៉ុន្មាន យកទៅធ្វើជាសៀវភៅ ឬមួយក៏ទុកជាឲ្យក្មេងក្រោយៗបានរៀនបានសូត្រអីចឹងអ្នកស្រាវជ្រាវបានដឹង ។

ឆ្លង ៖ អឺ! ស្រេចចៅដាក់ស្រេចយ៉ាងណាក៏ធ្វើទៅ យើងយកផ្សំគ្នាចុះ ផ្សំពីខាងនេះមួយ ផ្សំពីខាងនោះមួយផ្សំពីខាងនោះមួយៗ យកមកបញ្ចូលគ្នា ។

ធានី ៖ ចា៎!ចឹងសុំអនុញ្ញាតិលោកតាសិន?

ឆ្លង ៖ ទៅបានដាក់ជាកម្រង ។

ធានី ៖ កម្រងសៀវភៅឲ្យក្មេងៗក្រោយ ។ ចឹងចៅសុំថតជារូបអីបានទេ?

ឆ្លង ៖ បាន មានអី ។

ធានី ៖ ចឹងអរគុណច្រើនលោកតា ។

«ចប់»